ATASK គឺជាភ្នាក់ងារប្រឆាំងអំពើហិង្សាក្នុងគ្រួសារសម្រាប់ជនរងគ្រោះជាតិសាសន៍អាស៊ី និងអ្នករួចផុតពីគ្រោះថ្នាក់នៅ ញូ អ៊ីងឡែន ដោយបម្រើអតិថិជនជាភាសាអាស៊ីចំនួន 14 ភាសា។ បេសកកម្មរបស់យើងគឺដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារក្នុងចំណោមគ្រួសារ និងសហគមន៍អាស៊ី និងដើម្បីផ្តល់ក្តីសង្ឃឹមដល់អ្នករួចផុតពីគ្រោះថ្នាក់។

**បូស្តុន៖**
ប្រអប់សំបុត្រលេខ 120108
Boston, MA 02112
ទូរសព្ទ៖ (617) 338-2350
ទូរសារ៖ (617) 338-2354

**ឡូវែល៖**
ប្រអប់សំបុត្រលេខ 7259
Lowell, MA 01853
ទូរសព្ទ៖ (978) 454-3651
ទូរសារ៖ (978) 937-2355

## ខ្សែទូរសព្ទជំនួយទាក់ទងនឹងអំពើហិង្សាក្នុងគ្រួសារ

ពហុភាសា 24 ម៉ោង

## (617) 338-2355

- បាំងក្លា
- វៀតណាម
- ចិនកាតាំង
- តៃវ៉ាន់
- ឥណ្ឌូណេស៊ី
- ហិណ្ឌី
- នេប៉ាល់
- អ៊ូឌូ
- ថៃ
- កាតាឡុក (ហ្វីលីពីន)
- ចិនកុកងឺ មៀន
- ខ្មែរ (កម្ពុជា)
- ជប៉ុន
- កូរ៉េ
- ម៉ានីពូរី

*គម្រោងនេះត្រូវបានគាំទ្រដោយជំនួយរដ្ឋាភិបាលលេខ 2014-WL-AX-0036 ដែលផ្តល់ដោយការិយាល័យប្រឆាំងអំពើហិង្សាលើស្ត្រីនៃក្រសួងយុត្តិធម៌សហរដ្ឋអាមេរិក។ មតិ លទ្ធផលរកឃើញ សេចក្តីសន្និដ្ឋាន និងអនុសាសន៍នានា ដែលបានបង្ហាញនៅក្នុងឯកសារបោះពុម្ពផ្សាយ/កម្មវិធី/ពិព័រណ៍នេះគឺជារបស់អ្នកនិពន្ធ ហើយមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ក្រសួងយុត្តិធម៌ ការិយាល័យប្រឆាំងអំពើហិង្សាលើស្ត្រីនោះទេ។

សំណួរសួរញឹកញាប់ ដែលសរសេរដោយកម្មវិធីតស៊ូមតិផ្នែកច្បាប់ ATASK។ កំណែចុងក្រោយ ថ្ងៃទី 31 ខែឧសភា ឆ្នាំ 2016

**ASIAN TASK FORCE**
Against Domestic Violence

# លំនៅ អត្ថប្រយោជន៍សាធារណៈ និង សិទ្ធិប្រើប្រាស់ភាសា

## សំណួរដែលសួរញឹកញាប់

### កម្មវិធីតស៊ូមតិផ្នែកច្បាប់

ខ្សែទូរសព្ទជំនួយពហុភាសា 24 ម៉ោង

**(617) 338-2355**

www.atask.org

## ត្រូវការជំនួយបន្ថែមមែនទេ?

ក្នុងករណីបន្ទាន់ សូមទូរសព្ទទៅកាន់ 911

| | |
|---|---|
| Safelink | 1-877-785-2020 |
| | 1-877-521-2601 |
| Greater Boston Legal Services | 617-371-1234 |
| | 800-323-3205 |
| Legal Advocacy and Resource Center, Inc. | 617-603-1700 |
| | 800-345-5297 |
| Metro West Legal Services | 508-620-1830 |
| | 800-696-1501 |
| Northeast Legal Aid | 978-458-1465 |
| | 800-336-2262 |
| National Lawyers Guild | 617-227-7008 |
| Boston Bar Association Lawyer Referral Service | 617-742-0625 |
| | 800-552-7046 |
| Massachusetts Bar Association | 617-654-0400 |
| | 866-627-7577 |

ASIAN TASK FORCE
Against Domestic Violence

# កម្មវិធីតស៊ូមតិផ្នែកច្បាប់

កម្មវិធីតស៊ូមតិផ្នែកច្បាប់របស់យើងខិតខំបំពេញចន្លោះខ្វះខាតសំខាន់ៗនៅក្នុងការផ្តល់សេវាផ្នែកច្បាប់ដោយឥតគិតថ្លៃដល់ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ និងការប្រទូស្តកេរ្តិ៍ភេទនៃមរតកអាស៊ី ឬអាមេរិកអាស៊ី។

ចាប់តាំងពីពេលបង្កើតឡើងនៅឆ្នាំ 2009 យើងបានផ្តល់សេវាតស៊ូមតិ ភាពជាតំណាង និងការប្រឹក្សាយោបល់ផ្នែកច្បាប់ដល់អតិថិជនរបស់ ATASK ដើម្បីជួយធានាសិទ្ធិស្របច្បាប់របស់ពួកគាត់ក្នុងការក្លាយជាបុគ្គលឯករាជ្យ និងមានសុវត្ថិភាព រួចផុតពីការប្រើអំណាច និងការគ្រប់គ្រងរបស់ជនបំពាន។

ប្រវត្តិសហការរបស់យើងជាមួយអង្គការតាមសហគមន៍ សាលានីតិសាស្ត្រ សេវាផ្នែកច្បាប់ និងមេធាវីជួយជនក្រីក្រ មានន័យថា យើងធ្វើការយ៉ាងហ្មត់ចត់ ដើម្បីធានាថា អ្នករួចផុតពីគ្រោះថ្នាក់មិនត្រូវបានបដិសេធក្នុងការទទួលបានភាពជាតំណាងផ្នែកច្បាប់ ជំនួយយុទ្ធសាស្ត្រ ការណែនាំ ឬការបញ្ជូនដោយជោគជ័យ។

ការបដិសេធទទួលខុសត្រូវ៖ ខ្លឹមសារក្នុងទំព័រនេះមានគោលបំណងផ្តល់ព័ត៌មានតែប៉ុណ្ណោះ ហើយមិនមែនជាការផ្តល់ប្រឹក្សាផ្នែកច្បាប់នោះទេ។ មុននឹងអ្នកសម្រេចធ្វើសកម្មភាពណាមួយ ATASK លើកទឹកចិត្តឱ្យអ្នកស្វែងរកការប្រឹក្សាយោបល់ពីមេធាវីនៅរដ្ឋម៉ាសាឈូសេតស៍ ដើម្បីជួយអ្នកវិភាគលើស្ថានភាពពិសេស និងជាក់លាក់របស់អ្នក ដើម្បីស្វែងរកដំណោះស្រាយល្អបំផុត ដែលស្របតាមតម្រូវការរបស់អ្នក។

# លំនៅ និងសិទ្ធិអ្នកជួល

## ប្រសិនបើអ្នកបំពានលើខ្ញុំ និងខ្ញុំចែកផ្លូវគ្នា តើខ្ញុំអាចស្នាក់នៅផ្ទះរបស់ខ្ញុំជាមួយកូនរបស់ខ្ញុំទេ?

នៅពេលអ្នកដាក់ពាក្យសុំដីកាទប់ស្កាត់ការបំពាន 209A អ្នកអាចស្នើឱ្យដៃគូដែលបំពានលើអ្នកចាកចេញពីផ្ទះរបស់អ្នកជាបណ្ដោះអាសន្នសិន។

ចៅក្រមតុលាការដោះស្រាយបញ្ហាគ្រួសារក៏អាចសម្រេចថាតើនរណានឹងនៅផ្ទះក្នុងចំណងអាពាហ៍ពិពាហ៍ក្នុងរយៈពេលវែង។ ជាទូទៅ តុលាការនឹងអនុញ្ញាតឱ្យមាតា/បិតាចម្បងរបស់កូនស្នាក់នៅផ្ទះនោះ យ៉ាងហោចណាស់ជាបណ្ដោះអាសន្នសិន។ ទោះបីជាអ្នកបំពានលើអ្នកគឺជាមេគ្រួសារក្នុងបញ្ជីគ្រួសារនៅក្នុងកិច្ចសន្យាជួលរបស់អ្នកក៏ដោយ ម្ចាស់ផ្ទះអាចត្រូវតម្រូវឱ្យប្ដូរទៅជាឈ្មោះអ្នកវិញ ប្រសិនបើអ្នកអាចបង្ហាញថាមានការបំពានមែន។

---

## តើមានអ្វីកើតឡើង ប្រសិនបើខ្ញុំស្ថិតក្នុងគ្រោះថ្នាក់ ហើយខ្ញុំត្រូវផ្លាស់

នៅរដ្ឋម៉ាសាឈូសេតស៍ ជនរងគ្រោះថ្មីៗនៃអំពើហិង្សាក្នុងគ្រួសារ ការប្រទូស្តកេរ្តិ៍ភេទ ការរំលោភសេពសន្ថវៈ ឬការឈ្លបចាប់ ដែលនៅតែរងការគំរាមកំហែងគ្រោះថ្នាក់ភ្លាមៗ អាចបញ្ចប់កិច្ចសន្យាជួលមុន ដោយគ្មានការពិន័យជាប្រាក់ ប្រសិនបើបានស្នើសុំសមរម្យ។ ប្រសិនបើអ្នកពិតជាបញ្ចប់កិច្ចសន្យាជួលមែន អ្នកនឹងនៅតែទទួលខុសត្រូវចំពោះខែដែលអ្នកបន្តនៅក្នុងផ្ទះល្វែងនោះ រហូតទាល់តែអ្នកចាកចេញ ហើយមនុស្សធំផ្សេងទៀត ដែលនៅបន្តកិច្ចសន្យាជួល នឹងនៅតែទទួលខុសត្រូវលើរយៈពេលសេសសល់ក្នុងកិច្ចសន្យាជួល។ អ្នកត្រូវផ្ដល់សេចក្ដីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់ម្ចាស់ផ្ទះរបស់អ្នកថា អ្នកគ្រោងបញ្ចប់កិច្ចសន្យាជួល ដោយសារអំពើហិង្សាមកលើអ្នក។ ម្ចាស់ផ្ទះរបស់អ្នកមានសិទ្ធិក្នុងការស្នើសុំភស្តុតាងជាឯកសារ។

អ្នកក៏អាចស្នើសុំម្ចាស់ផ្ទះឱ្យប្ដូរមេសោ និងលុបអ្នកបំពានចេញពីកិច្ចសន្យាជួលផងដែរ។

ប្រសិនបើអ្នកទូរសព្ទទៅនគរបាល សុំដីកាការពារ ឬស្នើសុំផ្លាស់ប្ដូរមេសោ ម្ចាស់ផ្ទះអាចនឹងមិនសងសឹកនឹងអ្នក ដោយដេញអ្នកចេញនោះទេ

អ្នកមានសិទ្ធិទាំងនេះ មិនថាអ្នករស់នៅក្នុងផ្ទះឯកជន ឬសាធារណៈទេ ហើយទោះបីជាអ្នកមាន ឬគ្មានកិច្ចសន្យាជួលជាលាយលក្ខណ៍អក្សរក៏ដោយ។

# ជំនួយផ្នែកភាសា

## ចុះបើខ្ញុំមិនសូវចេះភាសាអង់គ្លេសវិញ? តើខ្ញុំអាចទាក់ទងទៅនរណា ដើម្បីជួយខ្ញុំទៅកាន់ប៉ុស្តិ៍នគរបាល តុលាការ ឬភ្នាក់ងាររដ្ឋាភិបាលបាន?

ទាំងនគរបាល ទាំងតុលាការមានកាតព្វកិច្ចតាមច្បាប់ក្នុងការផ្តល់អ្នកបកប្រែដល់អ្នកដោយឥតគិតថ្លៃ។ នៅពេលទាក់ទងជាមួយនគរបាល អ្នកអាចស្នើសុំអ្នកបកប្រែម្នាក់ដោយផ្ទាល់ជាមួយមន្ត្រីនគរបាល។ ប្រសិនបើអ្នកនៅក្នុងតុលាការ អ្នកអាចស្នើសុំអ្នកបកប្រែនៅតុលាការម្នាក់ជាមួយក្រឡាបញ្ជីម្នាក់។ ជាញឹកញាប់ DTA និងភ្នាក់ងារផ្តល់លំនៅឋានសាធារណៈនានាមានបុគ្គលិកដែលមានជំនាញភាសា។

អ្នកក៏អាចទាក់ទងមកយើងខ្ញុំនៅ Asian Task Force Against Domestic Violence ដើម្បីទទួលបានអ្នកតស៊ូមតិម្នាក់ ដែលចេះនិយាយភាសារបស់អ្នក ប្រសិនបើអ្នកត្រូវការការធ្វើឱ្យមានស្ថិរភាព និងជំនួយផ្នែកច្បាប់។

## តើមានកម្មវិធីផ្នែកច្បាប់ដែលមានមេធាវី ឬអ្នកតស៊ូមតិ ដែលចេះភាសារបស់ខ្ញុំទេ?

Greater Boston Legal Services, Asian Outreach Unit

http://www.gbls.org/our-work/asian-outreach

617-371-1234, 800-323-3205 (ឥតគិតថ្លៃ) ឬ 617-371-1228 (TDD)

The Asian Task Force Against Domestic Violence (ATASK)៖

http://www.atask.org/site/។

617-338-2355

សេវានានាពីកម្មវិធីនេះគឺឥតគិតថ្លៃសម្រាប់បុគ្គលដែលមានសិទ្ធិទទួលបាន។

## តើខ្ញុំអាចស្វែងរកលំនៅ/ជំរកបណ្តោះអាសន្ននៅកន្លែងណា ប្រសិនបើខ្ញុំរើចេញ?

ដើម្បីមើលបញ្ជីកន្លែងស្នាក់នៅ សូមចូលតាមតំណនេះ៖

http://www.womenshelters.org/cit/ma-boston

ដើម្បីស្វែងយល់បន្ថែមអំពីកន្លែងស្នាក់នៅដែលនៅក្បែរអ្នក អ្នកអាចទូរសព្ទទៅកាន់ "SafeLink។"

SafeLink គឺជាខ្សែទូរសព្ទបន្ទា**ន់ទាក់ទងនឹងបញ្ហាអំពើហិង្សាក្នុងគ្រួសារ** ដែលមានច្រើនភាសា និងឥតគិតថ្លៃរបស់រដ្ឋម៉ាសាឈូសេតស៍ ដែលអាចចូលទៅខ្សែទូរសព្ទបកប្រែភាសា ដើម្បីជួយអ្នកជាភាសាដើមរបស់អ្នក។ រាល់ការហៅទូរសព្ទទៅកាន់ SafeLink ត្រូវបានរក្សាការសម្ងាត់ជានិច្ច។

លេខទូរសព្ទ SafeLink គឺ (877) 785-2020។

លេខ TTY SafeLink សម្រាប់អ្នកដែលមានបញ្ហាស្តាប់គឺ (877) 521-2601។

គេហទំព័ររបស់ SafeLink គឺ http://www.casamyrna.org/

## ចុះមានជម្រើសស្នាក់នៅរយៈពេលវែងជាងនេះទេ?

កម្មវិធីស្នាក់នៅអន្តរកាលរបស់ Casa Myrna ផ្តល់កន្លែងស្នាក់នៅរយៈពេលវែង ដែលស្ត្រីអាចស្នាក់នៅរយៈពេលប្រមាណ 12 ទៅ18 ខែ នៅពេលពួកគាត់ស្វែងរកផ្ទះអចិន្ត្រៃយ៍។ជាធម្មតា ស្ត្រីស្នាក់នៅរយៈពេលចន្លោះ 12–14 ខែ ទោះបីជាអ្នកខ្លះអាចស្នាក់នៅរយៈពេល 18 ខែ ឬយូរជាងនេះ។

Casa Myrna ក៏មានកម្មវិធីថែទាំមនុស្សវ័យជំទង់ផងដែរសម្រាប់មនុស្សវ័យជំទង់ដែលមានផ្ទៃពោះ ឬកំពុងថែទាំកូន ដែលជាជនរងគ្រោះដោយសារការបំពាន។ រយៈពេលស្នាក់នៅជាធម្មតានៅកន្លែងនេះគឺចន្លោះ 12–14 ខែ។

ព័ត៌មានទំនាក់ទំនងរបស់ Casa Myrna គឺ៖

Casa Myrna Vazquez
ប្រអប់សំបុត្រ ប្រអប់លេខ 120108
Boston, MA 02112
617-338-2350 (ការិយាល័យ)
800-992-2600 (ខ្សែទូរសព្ទបន្ទាន់)

## តើខ្ញុំអាចស្វែងរកលំនៅអចិន្ត្រៃយ៍សម្រាប់អ្នកមានប្រាក់ចំណូលទាបដែលមានជំនួយនៅកន្លែងណា?

ប្រសិនបើអ្នកមានសញ្ជាតិអាមេរិក ឬមានឋានៈអន្តោប្រវេសន៍ផ្សេងទៀត អ្នកអាចមានសិទ្ធិទទួលបានកម្មវិធីស្នាក់នៅសហព័ន្ធជាច្រើន។

រដ្ឋម៉ាសាឈូសេតស៍ក៏ផ្តល់មូលនិធិ និងអនុវត្តកម្មវិធីស្នាក់នៅសាធារណៈមួយចំនួន ដែលមិនតម្រូវឱ្យមានសញ្ជាតិអាមេរិក ឬ មាន "ប័ណ្ណបៃតង" (Green Card) នោះទេ។ នៅពេលអ្នកទាក់ទងទៅកម្មវិធីអភិវឌ្ឍន៍លំនៅឋានសាធារណៈ ចូរសួរថាតើពួកគេមានបន្ទប់ស្នាក់នៅបែបនេះ ដែលទទួលបានមូលនិធិពីរដ្ឋទេ។

កម្មវិធីផ្តល់កន្លែងស្នាក់នៅមួយចំនួន ដែលទទួលបានមូលនិធិពីរដ្ឋ MA រួមមាន៖

- លំនៅឋានសាធារណៈរបស់រដ្ឋ (សម្រាប់គ្រួសារ និងបុគ្គលនៅលីវ)
- ប័ណ្ណស្នាក់នៅ Mass. Rental Voucher Program (MRVP)
- លំនៅឋានរបស់ភ្នាក់ងារហិរញ្ញប្បទានកន្លែងស្នាក់នៅនៃរដ្ឋម៉ាសាឈូសេតស៍ (MHFA) (បន្ទប់ស្នាក់នៅមួយចំនួនទទួលបានមូលនិធិពីរដ្ឋាភិបាលសហព័ន្ធ ដូច្នេះចូរសួររកតែបន្ទប់ណា ដែលឧបត្ថម្ភដោយរដ្ឋ)
- ប័ណ្ណស្នាក់នៅ Alternative Housing Voucher Program (AHVP) (សម្រាប់ជនពិការដែលមិនមែនចាស់ជរា)

ប្រសិនបើមានបញ្ជីរង់ចាំ អ្នកអាចត្រូវមានឈ្មោះនៅខាងលើនៃបញ្ជី ប្រសិនបើអ្នកមានសិទ្ធិទទួលបានពាក្យស្នើសុំ "បន្ទាន់" ដោយផ្អែកលើការគ្មានផ្ទះស្នាក់នៅភ្លាមៗ ឬដោយផ្អែកលើការផ្លាស់លំនៅដោយសារអំពើហិង្សាក្នុងគ្រួសារនាពេលថ្មីៗនេះ។ ត្រូវត្រៀមបបង្ហាញឯកសារដូចជា ដីការហាមឃាត់ កំណត់ហេតុវេជ្ជសាស្ត្រ ឬរបាយការណ៍ហេតុការណ៍របស់នគរបាល។

ប្រសិនបើអ្នកស្នាក់នៅក្នុងលំនៅសាធារណៈហើយ ប៉ុន្តែត្រូវរើចេញ ដោយសារអំពើហិង្សាក្នុងគ្រួសារ ចូរស្នើឱ្យផ្ទេរនៅបន្ទប់ស្នាក់នៅផ្សេងទៀត ដែលឧបត្ថម្ភដោយរដ្ឋ។

ប្រសិនបើអ្នកត្រូវផ្លាស់លំនៅចេញពីរដ្ឋម៉ាសាឈូសេតស៍ដោយហេតុផលសុវត្ថិភាព អ្នកនឹងមិនអាចប្រើប្រាស់សេវារបស់រដ្ឋ MA នេះទេ។ មានកម្មវិធីផ្តល់លំនៅសហព័ន្ធពិសេសមួយចំនួនផ្សេងទៀត ប៉ុន្តែមាននីតិវិធីដាក់ពាក្យពិសេសសម្រាប់អ្នកដែលមិនមានសញ្ជាតិអាមេរិកសម្រាប់កម្មវិធីទាំងនេះ។

## <u>ការរក្សាចំណូល/អត្ថប្រយោជន៍សាធារណៈ</u>

## ខ្ញុំពឹងផ្អែកលើដៃគូរបស់ខ្ញុំ ដើម្បីទទួលបានអត្ថប្រយោជន៍នានាដូចជា ធានារ៉ាប់រងសុខភាព។ តើខ្ញុំអាចនៅតែទទួលបានអត្ថប្រយោជន៍របស់ខ្ញុំទៀតទេ ប្រសិនបើខ្ញុំចែកផ្លូវពីដៃគូ/ប្តីរបស់ខ្ញុំ?

ប្រសិនបើអ្នកមានសញ្ជាតិអាមេរិក ឬជានិវាសនជនអចិន្ត្រៃយ៍ស្របច្បាប់ ហើយអ្នកមានចំណូលទាបខ្លាំង អ្នកអាចដាក់ពាក្យស្នើសុំអត្ថប្រយោជន៍ពីរដ្ឋាភិបាលដូចជា ការគ្របដណ្តប់លើសេវាថែទាំសុខភាព ឬលតាបត្រប្តូរយកអាហារដោយខ្លួនឯង។

ប្រសិនបើអ្នកមិនមាន "ប័ណ្ណបៃតង" អ្នកនៅតែអាចទទួលបានអត្ថប្រយោជន៍មានកំណត់មួយចំនួន។ ការសំខាន់គឺត្រូវនិយាយទៅកាន់អ្នកតស៊ូមតិម្នាក់នៅក្នុងកម្មវិធីប្រឆាំងអំពើហិង្សាក្នុងគ្រួសារ ឬទៅកាន់មន្ទីរជំនួយអន្តរកាល (ការិយាល័យនៅតំបន់របស់អ្នកអាចរកបាននៅទីនេះ http://webapps.ehs.state.ma.us/DTAOffices/default.aspx)

ដើម្បីកំណត់សិទ្ធិទទួលបានរបស់អ្នក។

ប្រសិនបើការគ្របដណ្តប់សេវាថែទាំសុខភាពរបស់អ្នកពីមុនត្រូវបានផ្តល់ឱ្យតាមរយៈប្តីរបស់អ្នកតាមរយៈការងាររបស់គាត់ ចៅក្រមអាចចេញដីកាឱ្យប្តីរបស់អ្នកបន្តគ្របដណ្តប់លើតម្រូវការធានារ៉ាប់រងសុខភាពរបស់អ្នកនៅក្នុងករណីខ្លះ។

## តើមានអត្ថប្រយោជន៍សាធារណៈណាមួយ ដើម្បីជួយខ្ញុំឱ្យមានឯករាជ្យភាពផ្នែកហិរញ្ញវត្ថុពីដៃគូបំពានលើខ្ញុំដែរឬទេ?

- មន្ទីរជំនួយអន្តរកាល (DTA) នៃរដ្ឋម៉ាសាឈូសេតស៍ ផ្តល់៖ ជំនួយជាអាហារ ជំនួយជាសាច់ប្រាក់ ជំនួយស្វែងរកការងារ ជម្រកគ្រាអាសន្ន និងជំនួយទាក់ទងនឹងអំពើហិង្សាក្នុងគ្រួសារ សម្រាប់ពលរដ្ឋអាមេរិក និងនិវាសនជនអចិន្ត្រៃយ៍ស្របច្បាប់ និងអ្នកដែលមិនមែនជាជនអន្តោប្រវេសន៍មួយចំនួនទៀត។
- ដើម្បីដឹងថាតើអ្នកមានសិទ្ធិទទួលបានអត្ថប្រយោជន៍ជាក់លាក់ណាមួយ អ្នកអាចចូលទៅកាន់ការិយាល័យ DTA ដែលនៅជិតអ្នកបំផុត ដើម្បីដាក់ពាក្យស្នើសុំ។ ចូរចងចាំថា ត្រូវរក្សាលិខិតបដិសេធ ឬយល់ព្រមរបស់អ្នកជានិច្ច